ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ការរកឃើញ ០៤ ករណីថ្មីទៀត ជាបុរសជនជាតិខ្មែរ ពិជ្ជមានវីរុសកូវីដ១៩ និង អ្នកព្យាបាលជាសះស្បើយ ជាបុរសជនជាតិខ្មែរ ០២ នាក់ នៅរាជធានីភ្នំពេញ

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. សរុបស្ថានភាពអ្នកជំងឺនៅទូទាំងប្រទេស៖** ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២០

- អ្នកដែលបានព្យាបាលជាសះស្បើយ សរុបមានចំនួន ១៣ នាក់ (បុរសជនជាតិចិន ០១ នាក់ ស្ត្រីជនជាតិអង់គ្លេស ០១នាក់ បុរសជនជាតិខ្មែរ ១១នាក់) គិតពីខែមករា ដល់បច្ចុប្បន្ននេះ
- អ្នកដែលកំពុងនៅសម្រាកព្យាបាល សរុបចំនួន ៩១នាក់ (ស្ត្រី ២៦នាក់ និងបុរស ៦៥នាក់) នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត
- ករណីវិជ្ជមានវីរុសកូវីដ១៩ ដែលបានរកឃើញទាំងអស់នៅទូទាំងប្រទេស សរុបចំនួន ១០២ នាក់ (ស្រី ២៧នាក់ ប្រុស៧៥នាក់) ។

<u>សម្គាល់៖</u> អ្នកដែលបានជាសះស្បើយមាន បុរសអាយុ ៦៤ឆ្នាំ នៅរាជធានីភ្នំពេញ និង បុរសអាយុ ៥១ ឆ្នាំ នៅខេត្តបន្ទាយមានជ័យ។

**២. លទ្ធផលវិភាគ៖**

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ មិនមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩។ តែនៅថ្ងៃទី២៦ខែមីនា ឆ្នាំ២០២០ វេលាម៉ោង១១:០០នាទីយប់ លទ្ធផលវិភាគទទួលបានពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានរកឃើញ វិជ្ជមានវីរុសកូវីដ១៩ ចំនួន០៤ករណីថ្មីទៀត មានដូចតទៅ៖

**ក. នៅរាជធានីភ្នំពេញ៖ ០៤ ករណី ជាជនជាតិខ្មែរ**

គ្រួសារមួយនៅរាជធានីភ្នំពេញ ដែលមានបុរសអាយុ ៦២ឆ្នាំ (ជាឪពុក) ស្ត្រីអាយុ ៦១ឆ្នាំ (ជាម្តាយ) បុរសអាយុ៣៩ឆ្នាំ (ជាកូន) និងស្ត្រីអាយុ ៣៧ឆ្នាំ (ជាកូន) មានតេស្តវិជ្ជមានវីរុសកូវីដ១៩។ បច្ចុប្បន្នពួកគាត់ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែក្រោម រាជធានីភ្នំពេញ ។ ក្រុមគ្រួសារនេះ បានធ្វើដំណើរទៅប្រទេសបារាំង ហើយពេលត្រឡប់មកវិញ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០២០ បុរសអាយុ ៣៩ឆ្នាំ ក៏មានបញ្ហាសុខភាពតិចតួច រីឯក្រុមគ្រួសារគាត់០៣នាក់ទៀត បានវិលត្រឡប់មកផ្ទះវិញនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ក៏មានបញ្ហាសុខភាពតិចតួចដែរ។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ខ. នៅខេត្តស្វាយរៀង ៖ករណីជនជាតិចិន ១៧៨នាក់ ធ្វើដំណើរតាមជើងហោះហើរមួយមកពីហ្វីលីពីននៅថ្ងៃទី២៤ ខែមីនា ២០២០ ដើម្បីវិលត្រឡប់ទៅប្រទេសចិនវិញតាមជើងហោះហើរមួយទៀត ដែលត្រូវបន្តនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០។ ពួកគាត់ត្រូវបានធ្វើដំណើរមកសម្រាកនៅសណ្ឋាគារមួយនៅបាវិត ខេត្តស្វាយរៀង។ ក្នុងចំណោមជនជាតិចិន ១៧៨នាក់ មាន ០២នាក់ មានបុរសអាយុ ២៦ឆ្នាំ និងបុរសអាយុ ៣២ឆ្នាំ មានអាការៈក្តៅខ្លួន ហើយមន្ទីរពេទ្យបង្អែកខេត្តស្វាយរៀង បានយកវត្ថុសំណាកទៅពិនិត្យនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩។ បច្ចុប្បន្ន បុរសទាំងពីរនាក់នេះ ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យខេត្តស្វាយរៀងនៅថ្ងៃនេះ។

៣. លទ្ធផលដែលនឹងត្រូវទទួលបាននៅវេលាចន្លោះម៉ោង២២ ទៅ២៣យប់ នៃថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០២០ នេះ នឹងជូនព័ត៌មានដល់សាធារណជននៅវេលាថ្ងៃស្អែកព្រឹកជាបន្តទៀត។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវឌ្ឍនៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសៅរ៍ ០៥កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា